**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៦ ឆ្នាំ២០២៣ ក្រោមប្រធានបទ "TVET ផ្តល់ជំនាញ និងការងារសមរម្យ"

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សិស្ស និស្សិត យុវជន កម្មករនិយោជិត មាតាបិតា អាណាព្យាបាល និងសាធារណជន ជាពិសេសបណ្តាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជ្រាបថា ក្រសួងនឹងប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៦ ឆ្នាំ២០២៣ ក្រោមប្រធានបទ "TVET ផ្តល់ជំនាញ និងការងារសមរម្យ" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥-១៦ ខែមិថុនា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ២០:០០នាទីយប់ នៅអគារពិព័រណ៍ពាណិជ្ជកម្មកោះពេជ្រ រាជធានីភ្នំពេញ។ ទិវាជាតិនេះ ក្រសួងនឹងរៀបចំដាក់តាំងបង្ហាញពីវឌ្ឍនភាពនៃវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានការចូលរួមពីក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សាវិស័យឯកជន ដៃគូអភិវឌ្ឍ និងផ្នែកពាក់ព័ន្ធនានា សរុបចំនួន ៩៥អង្គភាព ព្រមទាំងមានការធ្វើបាឋកថាចែករំលែកបទពិសោធន៍ពីវាគ្មិនល្បីៗ និងកម្មវិធីសំខាន់ៗដូចជា៖

១. ការធ្វើបាឋកថាអប់រំផ្លូវចិត្ត និងពុទ្ធឱវាទរបស់ ព្រះមេធានុវ័ឌ្ឍបណ្ឌិត គូ សុភាព ព្រះធម្មធរគណរាជធានីភ្នំពេញ និងជាព្រះគ្រូសូត្រស្តាំវត្តនិគ្រោធវ័នគល់ទទឹង
២. ការធ្វើបាឋកថាស្តីពីសារៈសំខាន់នៃការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដោយ អ្នកឧកញ៉ា គួច ម៉េងលី ស្ថាបនិក ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន
៣. ការធ្វើបាឋកថាស្តីពីសារៈសំខាន់នៃជំនាញទន់នៅកន្លែងការងារ ដោយ ឯកឧត្តម ឃីម សុខហេង ស្ថាបនិកវិទ្យាស្ថានសិក្សាដើម្បីជោគជ័យ
៤. ការទស្សនាការបង្ហាញ Computer Science (Web Design, Software and Graphic Design), ការតបណ្តាញអគ្គិសនី និងម៉ាស៊ីនស្វ័យប្រវត្តិកម្ម (Automation) របស់និស្សិតដែលទទួលបានជ័យលាភីក្នុងការប្រកួតប្រជែងជំនាញថ្នាក់ជាតិលើកទី៨ ឆ្នាំ២០២២
៥. ការទស្សនាពិព័រណ៍វឌ្ឍនភាពវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ព្រមជាមួយគ្នានេះ ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៦ ឆ្នាំ២០២៣ ក្រោមប្រធានបទ "TVET ផ្តល់ជំនាញ និងការងារសមរម្យ" ក៏នឹងប្រារព្ធព្រមគ្នានៅគ្រប់ខេត្តទូទាំងប្រទេសផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សិស្ស និស្សិត យុវជន កម្មករនិយោជិត មាតាបិតា អាណាព្យាបាល និងសាធារណជន ជាពិសេសបណ្តាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជ្រាបជាព័ត៌មាន និងចូលរួមទស្សនាដោយសេរី។

ថ្ងៃពុធ ១១រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

សូមទំនាក់ទំនងលេខទូរស័ព្ទ៖
- ០១៧ ៧៤៧ ៧៧៣
- ០១២ ២២៣ ១៨៩